**អភិបូជាបើកឆ្នាំសិក្សាថ្មីរបស់ទេវវិទ្យាល័យ សន្តយ៉ូហានម៉ារីវីយ៉ាណេ**

**ភ្នំពេញថ្មី ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១**

**“ធ្វើជាទូតរបស់ព្រះគ្រីស្ត”**

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ដែលយើងបើកឆ្នាំសិក្សាថ្មីរបស់ទេវវិទ្យាល័យ សន្តយ៉ូហានម៉ារីវីយ៉ាណេ យើងបានទទួលដំណឹងល្អដែលបំភ្លឺយើងមែនទែន។ ជាពិសេសថ្ងៃនេះ យើងសប្បាយចិត្តស្តាប់លោកប៉ូលដែលនិយាយថា “**បងប្អូនជាទីស្រឡាញ់ ខ្ញុំមិនខ្មាស់នឹងប្រកាសដំណឹងល្អទេ ព្រោះដំណឹងល្អនេះជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ សម្រាប់សង្គ្រោះអស់អ្នកដែលជឿសង្ឃឹមលើព្រះអង្គ គឺមុនដំបូងសាសន៍យូដា បន្ទាប់មកសាសន៍ក្រិច**” ហើយបន្តមកទៀតជនជាតិខ្មែរ។ ហេតុនេះហើយ យើងបានចូលនៅក្នុងទីជម្រៅនៃបេសកកម្មរបស់យើង ជាពិសេសនៅក្នុងខែតុលានេះ ជាខែដែលយើងត្រូវអធិដ្ឋានដើម្បីឱ្យព្រះសហគមន៍យកចិត្តទុកដាក់ថែមទៀត ក្នុងការប្រកាសដំណឹងល្អ។ ប៉ុន្តែ ការប្រកាសដំណឹងល្អណែនាំឱ្យយើងត្រូវតែមើលឃើញ អ្វីៗដែលភ្នែករបស់យើងទូទៅមើលមិនឃើញ។

នៅក្នុងទំនុកតម្កើង “**ផ្ទៃមេឃថ្លាថ្លៃង រុងរឿងស្ញប់ស្ញែង របស់ព្រះម្ចាស់ អាកាសវេហាស៍ ក៏បានប្រកាស ពីស្នាព្រះហស្ត របស់ព្រះអង្គ**”។ ប្រសិនបើ យើងចេះបើកភ្នែកយើងអាចមើលឃើញយ៉ាងជាក់ស្តែង អំពីវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងប្រចាំ។ តាមរយៈអាកាសវេហាស៍ តាមរយៈអ្វីៗដែលព្រះជាម្ចាស់បានបង្កើត តាមស្នាដៃរបស់ព្រះអង្គនៅកន្លែងនីមួយៗ នៅក្នុងជីវិតរបស់យើងប្រចាំ។ ប៉ុន្តែ ប្រហែលជាពេលវេលាដើម្បីសួរខ្លួនឯងដែរ **តើយើងបានមើលឃើញសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះជាម្ចាស់ នៅក្នុងពិភពលោក នៅក្នុងជីវិតរបស់យើងឬទេ? តើយើងធ្វើដូចម្តេចដើម្បីណែនាំឱ្យបងប្អូនឯទៀតៗ អាចមើលឃើញវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងពិភពរបស់យើងបច្ចុប្បន្ននេះ និងស្នាព្រះហស្តរបស់ព្រះអង្គនៅក្នុងពិភពលោកសព្វថ្ងៃដែរ?** “ដោយសារខ្ញុំមិនខ្មាស់នឹងប្រកាសដំណឹងល្អទេ ព្រោះដំណឹងល្អនេះជាឫទ្ធានុភាពរបស់ព្រះជា

**ម្ចាស់ សម្រាប់សង្គ្រោះអស់អ្នកដែលជឿសង្ឃឹមលើព្រះអង្គ**។ គោលដៅនៃជីវិតរបស់យើងគឺហ្នឹង មនុស្សសុចរិតដោយសារជំនឿយើងមានជីវិត យើងចង់មានជីវិត ជីវិតរបស់យើងយើងអាច ទទួលនៅក្នុងជំនឿទៅលើព្រះអង្គតែម្តង។

បងប្អូនជាទីស្រឡាញ់ នៅក្នុងរយៈពេលប៉ុន្មានខែដែលយើងរស់នៅក្នុងបរិយាកាសនៃជំងឺកូវីដ-១៩ ខ្ញុំគិតថាសម្រាប់កូនសិស្សលោកអភិបាលក៏ជាពេលវេលាមួយដើម្បីគិតពិចារណាដែរ។ **តើនៅក្នុងរដូវកូវីដ-១៩យើងបានរៀនអ្វីខ្លះ? តើយើងបានរៀនអ្វីខ្លះនៅក្នុងជីវិតរបស់យើងជាអ្នកប្រកាសដំណឹងល្អ? តើយើងបានរៀនអ្វីខ្លះនៅក្នុងជីវិតរបស់យើង ដែលកំពុងត្រៀមខ្លួនទៅជាបូជាចារ្យបម្រើព្រះសហគមន៍ និងបម្រើមនុស្សលោក?** ប្រកាសដំណឹងល្អដើម្បីឱ្យមនុស្សយ៉ាងច្រើនទទួលជីវិត គឺជីវិតអស់កល្បជានិច្ច។ ខ្ញុំគិតថាយើងទាំងអស់គ្នាបានរៀនយ៉ាងតិច៣ចំណុចដ៏សំខាន់គឺ៖

**ចំណុចទី១** យើងបានរៀនអំពី**សារៈសំខាន់នៃទំនាក់ទំនង** ប្រសិនបើយើងបាត់បង់ទំនាក់ទំនងផ្ទាល់ **តើយើងធ្វើដូចម្តេចដើម្បីប្រកាសដំណឹងល្អ?** ប្រសិនបើយើងបាត់បង់ទំនាក់ទំនងផ្ទាល់ **តើយើងធ្វើដូចម្តេចដើម្បីឱ្យការប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ ដំណឹងល្អដែលយើងបានស្តាប់ថ្ងៃនេះ ទៅដល់មនុស្សយ៉ាងពិតប្រាកដ?** ពិតមែនយើងមានមធ្យោបាយទំនើបៗច្រើន យើងអាចប្រជុំ/សិក្ខាសាលាពីចម្ងាយ យើងមានហ្វេសបុក យើងមានយូធូប យើងមានការផ្សាយអភិបូជាពីចម្ងាយ យើងមានកម្មវិធីច្រើនដើម្បីប្រកាសដំណឹងល្អ។ តាមរយៈមធ្យោបាយទាំងអស់នេះ **តើយើងអាចប្រកាសដំណឹងល្អដល់ណា?** ជួនកាលមានរាប់ម៉ឺននាក់ដែលមើល ប៉ុន្តែពេលមានរាប់ម៉ឺននាក់ដែលមើលគឺនៅពេលយើងពិចារណាអំពីរឿងប្លែក ដូចជាវប្បធម៌ របាំ...។ ប៉ុន្តែ នៅពេលយើងចូលនៅក្នុងជំនឿយ៉ាងជ្រៅ ពិបាកដើម្បីឱ្យគេចូលមើល។ ដោយសារការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូ គឺព្រះអង្គបានដើរពីភូមិមួយទៅភូមិមួយ ព្រះអង្គទៅជួបជាមួយមហាជន ព្រះអង្គអង្គុយជាមួយក្រុមសាវ័ក ព្រះអង្គចាប់ដៃអ្នកជំងឺ ព្រះអង្គនៅជាមួយអ្នកបាប ព្រះអង្គហូបបាយជាមួយគេ។ ហេតុនេះហើយ ទំនាក់ទំនងផ្ទាល់មានសារៈសំខាន់បំផុត ដែលយើងយល់ថានៅរដូវកូវីដ-១៩នេះ ណែនាំឱ្យយើងបាត់ទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ។ តួនាទីរបស់យើង គឺណែនាំឱ្យដំណឹងល្អទៅដល់ជីវិតរបស់បងប្អូនឯទៀតៗ តាមរយៈ ZOOM ហ្វេសបុក យូធូប តាមរយៈទំនាក់ទំនងសប្បនិមិត្តមិនអាចចូលដល់ជីវិតបងប្អូនបានទេ។ ព្រះសហគមន៍របស់យើង បានរីកចម្រើនពីសម័យដំបូងមុនគេបង្អស់ជាមួយសាសន៍យូដា បន្ទាប់មកសាសន៍ក្រិច បន្ទាប់មកសាសន៍រ៉ូម៉ាំង បន្ទាប់មកអឺរ៉ុប អាមេរិក អាហ្វ្រិច អាស៊ី។ បានទៅដល់កន្លែងទាំងនោះ ដោយសារអ្នកប្រកាសដំណឹងល្អបានធ្វើដំណើរទៅដល់កន្លែង។ ការធ្វើដំណើរពីដើម គឺថ្មើរជើង ក្រោយមក

ជិះកប្បាល់ទឹក ក្រោយមកទៀតជិះយន្តហោះ ប៉ុន្តែយើងបានធ្វើដំណើរទៅដល់ទីកន្លែង ដើម្បីបង្កើតទំនាក់ទំនង។ បង្កើតទំនាក់ទំនងដូចព្រះយេស៊ូពីដើម អង្គុយជាមួយស្ត្រីសាសន៍សាម៉ារី ដើម្បីបង្ហាញប្រសិនបើនាងដឹងអំពីអំណោយទានរបស់ព្រះជាម្ចាស់។ ដូច្នេះ បងប្អូនជាទីស្រឡាញ់យើងត្រូវការថែរក្សាទំនាក់ទំនងតទៅទៀត ដោយយល់ថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដំណឹងល្អរបស់ព្រះជាម្ចាស់អាចចូលនៅក្នុងដួងចិត្តរបស់បងប្អូនឯទៀតៗបាន លុះត្រាតែយើងអង្គុយដើម្បីជួបគ្នា ដើម្បីបង្កើតទំនាក់ទំនងដ៏ពិតប្រាកដ។

**ចំណុចទី២** នៅក្នុងរដូវកូវីដ-១៩នេះយើងបានយល់ដែរ អំពី**សារៈសំខាន់នៃការសិក្សា** ដោយសារនៅពេលយើងខ្វះយើងយល់អំពីអ្វីដែលមានសារៈសំខាន់។ នៅពេលរដ្ឋាភិបាលប្រកាសបិទសាលារៀនទាំងអស់ សិស្សសាលាត្រូវរៀនពីចម្ងាយ មានមួយចំនួនអាចរៀនបាន មួយចំនួនទៀតមិនអាចរៀនបាន។ ថ្ងៃនេះ នៅក្នុងការប្រជុំជាមួយលោកបូជាចារ្យភូមិភាគភ្នំពេញ យើងបានស្តាប់អំពីរបាយការណ៍របស់ការិយាល័យសិក្សាកាតូលិកភូមិភាគភ្នំពេញ។ យើញថា មានសាលាមត្តេយ្យមួយចំនួនបាត់កូនក្មេងច្រើន មានកូនក្មេងមួយចំនួនដែលបាត់បង់ការសិក្សាមួយឆ្នាំពីរឆ្នាំ នេះណែនាំឱ្យយើងឈឺចិត្តណាស់។ ប៉ុន្តែ ការសិក្សារបស់និស្សិតទេវវិទ្យាល័យមិនដែលបាត់មួយម៉ោង នេះដោយសារយើងបានរៀនពីចម្ងាយផង លោកមកបង្រៀនផ្ទាល់ផង ខ្ញុំសូមអរគុណដល់លោកគ្រូដែលបានយកចិត្តទុកដាក់បង្រៀន។ ការសិក្សាសំខាន់ណាស់ ដោយសារពេលយើងចង់ជួបជាមួយបងប្អូនឯទៀតៗ ដើម្បីនិយាយអំពីដំណឹងល្អយើងត្រូវការចូលនៅក្នុងដំណឹងល្អយ៉ាងច្បាស់លាស់ តាមរយៈការសិក្សារបស់យើង តាមទស្សនៈវិជ្ជា តាមទេវវិទ្យា តាមគម្ពីរវិទ្យា តាមសង្គមវិជ្ជា តាមព្រះសហគមន៍វិជ្ជា តាមវិជ្ជានីមួយៗដែលណែនាំឱ្យយើងចូលយ៉ាងជ្រៅនៅក្នុងអាថ៌កំបាំងនៃជំនឿ ដើម្បីឱ្យជីវិតរបស់យើងភ្ជាប់នៅក្នុងគ្រប់វិស័យជាមួយព្រះជាម្ចាស់។

**ចំណុចទី៣** នៅក្នុងពេលវេលានៃកូវីដ-១៩ យើងបានយល់អំពី**សារៈសំខាន់នៃការអធិដ្ឋាន** យើងមានពេលច្រើនជាងមុនដើម្បីអធិដ្ឋាន។ ជួនកាលយើងធ្លាប់និយាយថា ជីវិតរបស់យើងដូចជាជីវិតរបស់បងស្រីសម្ងាត់ដែរ។ ព្រោះថា បងស្រីសម្ងាត់តាមពិតជីវិតរបស់គាត់នៅតែដដែល ទោះបីមានកូវីដឬអត់មានកូវីដ នៅតែក្នុងអារាមអធិដ្ឋាន។ ប៉ុន្តែ សម្រាប់យើងជាបទពិសោធថ្មី ដោយសារ ប៉ុន្មានខែយើងបានរស់នៅក្នុងភាពសម្ងាត់ដែរ។ ដោយយល់ថា យើងនៅសល់ព្រះជាម្ចាស់ ដែលជួនកាលយើងមានអារម្មណ៍ថាឯកោ ប៉ុន្តែដោយសារយើងមានព្រះជាម្ចាស់យើងមិននៅម្នាក់ឯងទេ។ ការអធិដ្ឋាន ណែនាំឱ្យយើងភ្ជាប់ជាមួយព្រះជាម្ចាស់ ខ្ញុំជឿថានៅក្នុងពេលវេលាហ្នឹងយើងបានភ្ញាក់ស្មារតីសារជាថ្មី។ ការអធិដ្ឋានតាមមាលា គោរពព្រះកាយព្រះគ្រីស្ត អធិដ្ឋាន

តេហេ្ស អធិដ្ឋានពេលចូលអភិបូជា នេះបានណែនាំឱ្យព្រះសហគមន៍របស់យើងមានជីវិត និងផ្ទាល់ខ្លួនមានជីវិតភ្ជាប់ជាមួយព្រះជាម្ចាស់។

ហេតុនេះហើយ ទំនាក់ទំនង ការសិក្សា អធិដ្ឋាន អាចណែនាំឱ្យយើងទៅជាសាសនាទូតពិតមែន សាសនាទូតក្នុងន័យថាជាគ្រីស្តទូត។ ទូតរបស់ព្រះគ្រីស្ត ដើម្បីឱ្យការសង្គ្រោះបានទៅដល់បងប្អូនឯងទៀតៗ តាមរយៈការប្រកាសដំណឹងល្អ និងតាមរយៈអគ្គសញ្ញានានា។ បងប្អូនជាទីស្រឡាញ់ នៅក្នុងអាទិត្យនេះ យើងនឹងចូលនៅក្នុងសន្និបាតដើម្បីឱ្យយើងធ្វើដំណើររួមជាមួយគ្នា។ សប្តាហ៍មុនចេញពីទីក្រុងរ៉ូម អាទិត្យនេះទៅដល់ព្រះសហគមន៍នៅក្នុងភូមិភាគនីមួយៗ ដើម្បីឱ្យយើងរួមគ្នាជាមួយគ្នា។ នៅក្នុងឆ្នាំថ្មីនេះ ជាពេលវេលាសម្រាប់និស្សិតទេវវិទ្យាល័យ២នាក់ដែលនឹងត្រូវនៅរៀនបន្ត និស្សិតដែលត្រៀមទទួលអគ្គសញ្ញាតែងតាំងជាឧបដ្ឋាក ប្អូនយើងដែលរៀននៅប្រទេសថៃ និងប្អូនដែលត្រៀមទៅរៀននៅប្រទេសថៃ ដើម្បីថែរក្សាទំនាក់ទំនង ថែរក្សាការសិក្សា ថែរក្សាការអធិដ្ឋាន ដើម្បីទៅជាទូតរបស់ព្រះគ្រីស្តដ៏ពិតប្រាកដ ដែលចេះស្រឡាញ់ព្រះយេស៊ូ និងណែនាំឱ្យព្រះយេស៊ូទៅជាដំណឹងល្អសម្រាប់បងប្អូនឯទៀតៗ។ ពិតមែនការសង្គ្រោះណែនាំឱ្យយើងមានជីវិតជីវិតអស់កល្បជានិច្ច មុនគេបង្អស់គឺសាសន៍យូដា បន្ទាប់មកសាសន៍ក្រិច បន្ទាប់មកសាសន៍ខ្មែរ។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ៉ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ